# តារាងស្ដីពីព័ត៌មានរបស់គម្រោង

លេខPIP : 725

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : គម្រោងបែងចែកដីសង្គមកិច្ចសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចដំណាក់កាលទី២

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្ដើមគម្រោង 01/07/16

កាលបរិច្ឆេទបញ្ចប់គម្រោង 31/07/22

៣. ចំណាយគម្រោងសរុប $26,850,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

RESPONSIBLE UNIT General Department of Housing

អង្គភាពទទួលខុសត្រូវ អគ្គនាយកដ្ឋានលំនៅឋាន

៥. ស្ថានភាពគម្រោង គម្រោងដែលបានបញ្ចប់

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ ឥណទានសម្បទាន

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៤- ការពង្រឹងការប្រកួតប្រជែង

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

ការរួមចំណែករួមមាន៖ ផ្ដល់ដីសង្គមកិច្ចដល់អ្នកដែលមិនមានដីលំនៅឋាននិងដីកសិកម្ម
ផ្ដល់សេវាហេដ្ឋារចនាសម្ព័ន្ធរូបវន្តជនបទគ្រប់ប្រភេទដល់សម្បទានិក ផ្ដល់ការចុះបញ្ជីកម្មសិទ្ធកាន់កាប់ក្បាលដី
ផ្ដល់ការអប់រំនិងបណ្ដុះបណ្ដាលផ្នែកកសិកម្ម និងការជាំជុះដល់គ្រប់សម្បទានិក
ផ្ដល់សេវាមីក្រូហិរញ្ញវត្ថុខ្នាតតូចនិងកសាងហេដ្ឋារចនាសម្ព័ន្ធសង្គមរួមមានមណ្ឌលសុខភាព សាលារៀនជាដើម។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍនិវិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

កសិកម្ម និងការគ្រប់គ្រងដីធ្លី Land Management

**១២. ទីតាំងអនុវត្តគម្រោង** (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

ក្រចេះ, ត្បូងឃ្មុំ , កំពង់ធំ, កំពង់ឆ្នាំង, កំពង់ស្ពឺ,

**១៣. គោលបំណងរបស់គម្រោង** (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

គម្រោងចូលរួមគាំទ្រការអនុវត្តកម្មវិធីដីសង្គមកិច្ចដែលក្នុងនោះគឺបែងចែកដីទៅជូនគ្រួសារក្រីក្រគ្មានដីនិងលំនៅឋានដើម្បីសម្រួលកែលម្អជីវភាពគ្រួសារក្រីក្រទាំងនោះ
ដែលក្នុងនោះក្រៅពីការផ្ដល់ដីសម្រាប់លំនៅឋាននិងដីសម្រាប់កិច្ចការកសិកម្មគម្រោងធ្វើការកែលម្អជីវភាពសម្បទានីកចំនួន៥៤០០ គ្រួសារ ឲ្យមានជីវភាពសមរម្យតាមរយៈធនធានកសិកម្មនិងការផ្គត់ផ្គង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងសង្គមក្នុងទីតាំងទាំង៥នេះ។

**១៤. ការពិពណ៌នាអំពីគម្រោង** (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

សមាសភាគគម្រោងៈ គម្រោងនឹងគ្របដណ្តប់សរុបនៃទីតាំងសម្បទានដីសង្គមកិច្ចទាំង ១៥ទីតាំង ក្នុងខេត្ត ចំនួន៦គឺក្រចេះ ត្បូងឃ្មុំ កំពង់ធំ កំពង់ឆ្នាំង កំពង់ស្ពឺ និងបាត់ដំបង។ ទីតាំងទាំងនេះរួមទាំង ៨ទីតាំងរបស់ គម្រោង LASED ៦ទីតាំងក្រោមជំនួយហិរញ្ញប្បទាន JSDF តាមរយៈធនាគារពិភពលោក និងទីតាំងថ្មី ១ ក្នុងខេត្តកំពង់ធំ។ តំបន់សរុបដែលនឹងត្រូវគ្របដណ្តប់គឺប្រមាណ ១៧០០០ហិកតា ផ្តល់អត្ថប្រយោជដល់ប្រមាណ ៥៤០០គ្រួសារ។

គម្រោងនឹងកសាងពីបទពិសោធន៍ និងអនុវត្តជោគជ័យរបស់គម្រោងមុនៗ និងការអនុវត្តល្អៗក្នុងផ្នែក។ វានឹងសម្រេចសេចក្តីត្រូវការអាទិភាពដែលនូវសេសសល់របស់អ្នកទទួលផល តាមរយៈការផ្តល់កញ្ចប់ជំនួយបច្ចេកទេសកសិកម្ម និងផ្តល់ហេដ្ឋារចនាសម្ព័ន្ធដើម្បីឲ្យជីវិតរបស់គ្រួសារទាំងនោះមានផលិតភាព និងនិរន្តរភាព។ គម្រោងនឹងមានសមាសភាគចំនួន ២ ហើយនឹងត្រូវអនុវត្តក្នុងរយៈពេល ៥ឆ្នាំ។ យោងតាមបទពិសោធន៍ រយៈពេលគម្រោងគឺជាពេលវេលាអប្បបរមាតម្រូវឲ្យសម្រេចលទ្ធផល និងសមិទ្ធិផល ជាមួយនឹងនិរន្តរភាពនៃការវិនិយោគ និងការចិញ្ចឹមជីវិតនានា។

២.១ សមាសភាគ ១៖ ហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធចិញ្ចឹមជីវិត

សមាសភាគរង ១.១៖ ការកំណត់អាទិភាព និងរៀបចំផែនការវិនិយោគសម្បទានដីសង្គមកិច្ច។ សមាសភាគរងនេះនឹងគាំទ្រលើៈ (ក) ការរៀបចំផែនការដោយមានការចូលរួមសម្រាប់តីតាំងថ្មី និងធ្វើបច្ចុប្បន្នភាពនៃផែនការ SLC សម្រាប់តីតាំងដែលមានស្រាប់។ (ខ) កំណត់អត្តសញ្ញាណកម្ម កំណត់អាទិភាព និងផែនការនៃបច្ចេកទេសសមស្រប និងការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ និង (គ) ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិ ដល់អ្នកទទួលដីដែលមានមានលក្ខណៈសម្បត្តិត្រឹមត្រូវក្នុងទីតាំងដែលមានស្រាប់។

សមាសភាគរង ១.២៖ រៀបចំដី និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។ សមាសភាគរងនេះនឹងគាំទ្រតម្រូវការរៀបចំដី និងការវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាទិភាពក្នុងទីតាំងសម្បទានដីសង្គមកិច្ចទាំងនោះដូចជា (ក) ផ្តល់ជំនួយការតាំងទីលំនៅដល់អ្នកទទួលដីទើបចូលទៅរស់នោះ (ខ) ផ្តល់ជំនួយការចាប់ផ្តើមរៀបចំដីសម្រាប់ដំណាំគម្របដីដំបូង និង (គ) សាងសង់ហេដ្ឋារចនាសម្ព័ន្ធសហគមន៍សង្គម និងផលិតកម្មដូចជា ផ្លូវ ប្រព័ន្ធស្រោចស្រព្វខ្នាតតូច ទំនប់ស្ទាក់ទឹក ការផ្គត់ផ្គង់ទឹកជនបទ សាងសង់សាលារៀន ផ្ទះស្នាក់នៅរបស់គ្រូបង្រៀន ប៉ុស្តិ៍សុខភាព មណ្ឌលសហគមន៍ និងផ្សេងៗមួយចំនួនទៀត។ កិច្ចសហការ និងសហប្រតិបត្តិការជិតស្និទ្ធជាមួយ KfW ដែលនិងផ្តល់ហិរញ្ញប្បទានប្រហាក់ប្រហែលគ្នាលើហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដែលនឹងជួយបំពេញបន្ថែមការវិនិយោគគម្រោង។

សមាសភាគរង ១.៣៖ ការអភិវឌ្ឍកសិកម្ម និងការចិញ្ចឹមជីវិត។ សមាសភាគរងនេះនឹងជួយរួមបញ្ចូល និងការធ្វើឲ្យប្រសើរឡើងផ្សេងៗទៀតនៃប្រព័ន្ធផលិតកម្មកសិកម្ម ការចិញ្ចឹមជីវិត និងសុវត្ថិភាពស្បៀងរបស់គ្រួសារអ្នកទទួលដី រួមបញ្ចូលទាំងការសម្របសម្រួល និងផ្តល់នូវសេវាគាំទ្រ និងជំនួយបច្ចេកទេស។ ទាំងនេះនឹងរួមមានការឧបត្ថម្ភលើ (ក) ការរៀបចំសហគមន៍ និងការភអិវឌ្ឍ (ខ) ផ្តល់ការគាំទ្រលើការផ្សព្វផ្សាយ និងសេវាកម្ម យោងតាមទស្សនអ្នកផ្តល់សេវាកម្មចម្រុះ (គ) បង្កើតទីតាំងបង្ហាញ និងកសិកម្មគម្រូ (ឃ) ផ្តល់ការគាំទ្រទាំងសម្ភារ និងថវិកាដើម្បីពង្រឹងភាពជោគជ័យគំនិតផ្តួចផ្តើមមូលដ្ឋាន (ង) បង្កើត និងពង្រឹង សហគមន៍កសិកម្ម ក្រុមសន្សំ និងឥណទាន ក្រុមផលិត និងទីផ្សា និងក្រុមសហគមន៍ផ្សេងៗទៀត និង (ច) ភ្ជាប់ផែនការ SLC និងការអនុវត្តជាមួយនឹងផែនការអភិវឌ្ឍន៍ ឬវិនិយោគឃុំ (CDPs/CIPs)។

២.២ សមាសភាគ ២៖ ការគ្រប់គ្រងគម្រោង

សមាសភាគនេះនឹងគាំទ្រដល់ការគ្រប់គ្រងគម្រោង និងសកម្មភាពសម្របសម្រួលដទៃទៀត។ វានឹងធានាជាពិសេសដល់ការលំហូរសាច់ប្រាក់ការ ធ្វើលទ្ធកម្ម សវនកម្មនិងរបាយការណ៍។ វាក៏នឹងជួយគាំទ្រដល់គម្រោងអនុវត្តគម្រោងទាំងមូលនៅគ្រប់កម្រិត (រួមទាំងឃុំ) ដើម្បីពង្រឹងបន្ថែមទៀតចំពោះសមត្ថភាពរដ្ឋបាលនិងប្រព័ន្ធរបាយការណ៍។ យកចិត្តទុកដាក់ និងគាំទ្រជាក់លាក់នឹងត្រូវបានផ្តល់ដើម្បីពង្រីក និងពង្រឹងដល់ប្រព័ន្ធតាមដាននិងវាយតម្លៃរបស់គម្រោង។ ការគាំទ្រនេះនឹងរួមបញ្ចូលទាំងការផ្តល់ដល់គម្រោង និងប្រព័ន្ធព័ត៌មានគ្រប់គ្រង SLC ពាក់ព័ន្ធផ្សេងទៀត ដែលជាធាតុចូលទៅក្នុងផែនការ SLC និងសកម្មភាពអាទិភាពជាក់លាក់ តាមរយៈការកែសម្រួល និងកែលម្អការគ្រប់គ្រងប្រព័ន្ធព័ត៌មាន (MIS)។ ការគាំទ្រគួររួមមានជំនួយបច្ចេកទេស បណ្តុះបណ្តាល ចំណាយប្រតិបត្តិការ និងមធ្យោបាយធ្វើដំណើរ និងសម្ភារផ្សេងៗ។

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

១)គម្រោងចូលរួមកាត់បន្ថយភាពក្រីក្រតាមរយៈការផ្តល់ដីលំនៅឋាននិងដីកសិកម្ម ព្រមទាំងជួយផ្គត់ផ្គង់សំណង់ហេដ្ឋារចនាសម្ព័ន្ធជនបទ

២) គម្រោងចូលរួមការការពារបរិស្ថាននិងសង្គមតាមរយៈយន្តការគម្រោង

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

អ្នកទទួលផលផ្ទាល់ពីគម្រោងប្រមាណ ៥៤០០ គ្រួសារ ដែលធ្លាប់ជាក្រុមប្រជាពលរដ្ឋដែលគ្មានដី និងមានដីតិចតួច។ អ្នកទទួលផលទាំងនេះធ្លាប់បានផ្តល់នូវដីកសិកម្ម និងដីលំនៅឋាន ក្នុងទីតាំងសម្បទានដីសង្គមកិច្ចទាំង ១០ នៃគម្រោង LASED និង JSDF និងអ្នកដែលនឹងត្រូវបែងចែកដីនៅទីតាំងសម្បទានដីសង្គមកិច្ចទី១៥។ គម្រោងនឹងធ្វើការផ្តល់ជាក់លាក់ដើម្បីគាំទ្រគ្រួសារដែលងាយរងគ្រោះទាំងនោះ និងនឹងផ្តល់ការយកចិត្តទុកដាក់ជាក់លាក់លើសកម្មភាពចិញ្ចឹមជីវិតដែលផ្តល់អត្ថប្រយោជន៍ដល់ស្ត្រី។ សកម្មភាពដែលបានផ្តល់ហិរញ្ញប្បទានក្រោមគម្រោងនេះ នឹងបន្តប្រើប្រាស់ការរួមបញ្ចូលដំណើរការពិគ្រោះយោបល់ដែលបានបង្កើតឡើងក្នុងកំឡុងពេលអនុវត្តគម្រោងដំបូងដើម្បីបញ្ជាក់ និងឆ្លើយតបសេចក្តីត្រូវការរបស់គ្រួសារគោលដៅទាំងនោះ។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **គ្មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទាន់ចាប់ផ្តើម**

១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម (ពិពណ៌នាសង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?) គម្រោង LASED II ត្រូវបានចាត់ថ្នាក់បរិស្ថានក្នុងប្រភេទ "ខ" ដែលបានកំណត់ថា LASED II នៅបន្តតាមគោលការណ៍ការពារបរិស្ថានដែលធ្លាប់អនុវត្តនៅគម្រោងLASEDបច្ចុប្បន្ន សំដៅកាត់បន្ថយនិងកែសម្រួលនូវផលប៉ះពាល់លើបរិស្ថាន។ LASED II នឹងអនុវត្តនៅក្នុងតំបន់ LASEDបច្ចុប្បន្ន និង នៅក្នុងតំបន់ដែលផ្តល់មូលនិធិដោយJSDF និងនៅក្នុងតំបន់ថ្មី១ ស្ថិតនៅក្នុងឃុំជុង, ខេត្តកំពង់ធំ។ របាយការណ៍ត្រួតពិនិត្យនិងការពារសង្គមនិងបរិស្ថានត្រូវបានរៀបចំដោយទីភ្នាក់ងារអនុវត្តហើយត្រូវបានអនុម័តដោយអ្នកជំនាញការពារសុវត្ថិភាពបរិ ស្ថាននិងសង្គមរបស់ធនាគារពិភពលោកនៅក្នុងអំឡុងពេលរៀបចំគម្រោង LASED ដោយប្រើមូលនិធិបន្ថែមនាខែតុលាឆ្នាំ2013 ។សំណើរៀបចំដីសម្បទានសង្គមកិច្ចថ្មីនៅក្នុងឃុំជុងត្រូវបានផ្ទៀងផ្ទាត់ហើយបានអះអាងថាពិតតំបន់នេះជាមិនមែនតំបន់ព្រៃការពារឬចំណុចអភិរក្សបរិស្ថាន។ LASED II បានបង្កើតយន្តការសម្រាប់ការពារ គ្រប់គ្រងនិងពិនិត្យគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធ។ ចំណុចសើបចម្បង នៃការការពារបរិស្ថាន នឹងក្លាយជាប្រធានបទសម្រាប់ពង្រឹងការការពារបរិស្ថានបន្ថែមទៀតដែលកំណត់បាននូវវិធីការពារបរិស្ថានឲ្យកាន់តែប្រសើឡើង។ ការទទួលបានមូលនិធិតាមរយៈក្រុមឥណទាននិងក្រុមសន្សំក៏ជាប្រធានបទដែលទាមទារឲ្យអ្នកទទួលផល មានការប្តេជ្ញាចិត្តនៅក្នុងការអនុវត្តដើម្បីជានាកុំឲ្យមានគ្រោះថ្នាក់ដល់បរិស្ថាន។ គម្រោងបានគ្រោងថវិកាសម្រាប់ការបណ្តុះបណ្តាល ការអភិវឌ្ឍន៍ ដើម្បីបង្កើនសមត្ថភាព និងការត្រួតពិនិត្យ ការអនុវត្តប្រព័ន្ធសុវត្ថិភាព និងផ្សព្វផ្សាយអំពីការការពារបរិស្ថាន ដល់មន្ត្រីនៅថ្នាក់ក្រោមជាតិ។

១៩. ការប្រែប្រួល អាកាសធាតុ

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|
| | | |

២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ

| | |
|---|---|
| តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? | គ្មាន |

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

គម្រោងនេះចូលរួមអនុវត្តដោយស្ត្រីចំនួន៣០% ឆ្លើយតបទៅនឹងតម្រូវការរបស់គម្រោងផងដែរ។

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

គម្រោងបែងចែកកត្តព្វកិច្ចអ្នកទទួលខុសត្រូវរវាងស្ថាប័នទាំងបី ក្នុងនោះក្រសួង ជ.ន.ស ជានាយកគម្រោងទទួលខុសត្រូវលើការងារទូទៅនិងបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទទទួលបន្ទុកការងារបច្ចេកទេសកសិកម្ម និងស្ថាប័ន គ.ជ.អ.ប ទទួលបន្ទុកការងារលទ្ធកម្មនិងសម្របសម្រួលជាមួយថ្នាក់ក្រោមជាតិ។

២៣. ចំណែកក្រុមការងារអនុវត្តស្ថាប័ននីមួយៗមានអ្នកបច្ចេកទេសឯកទេសជំនាញផ្ទាល់ខ្លួន និងបុគ្គលិកការងារដែលស្ថាប័ននីមួយៗ ... បណ្តាល ឲ្យ ទទួលខុសត្រូវ។ ក្នុងនោះច្រើនអ្នកជំនាញនីមួយៗមានបទពិសោធន៍លើសពី១០ឆ្នាំឡើងទៅ។

គម្រោងបានចាប់ផ្តើមអនុវត្តពេញលេញពីខែសីហាឆ្នាំ២០១៦ ដោយភាគច្រើនគឺការងារដំណើរការលទ្ធកម្ម និងការចងការត្រួតពិនិត្យទីតាំគម្រោង និងការបែងចែកការងារទទួលខុសត្រូវតាមស្ថាប័ន និងកិច្ចការបន្សល់ពីជំហានទី១ខ្លះៗ។ ជាមួយនេះដែរ ក៏មានការងារធ្វើអត្តសញ្ញាណកម្មដីសម្បទានក្នុងតំបន់ថ្មីមួយកន្លែងផងដែរ។
ភាពប្រឈមរបស់គម្រោងនេះ
គឺការកំណត់ទីតាំងហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹកសម្រាប់តំបន់នីមួយៗដោយទីតាំងទាំង១៤ក្នុងគម្រោងមានកម្រិតកំពស់ខ្សែដីខ្ពស់ខ្លាំងពេក ដែលធ្វើឲ្យតំបន់នីមួយៗខ្វះខាតទឹកសម្រាប់ប្រជាកសិករធ្វើស្រែចំការ និងអាចប្រឈមនឹងការបោះបង់ចោលទីតាំងដីដែលបែងចែកទៅពួកគាត់។ ភាពប្រឈមមួយទៀតគឺ ជំហានទីមួយមិនបានចងក្រងទុកឯកសារគ្រប់គ្រាន់សម្រាប់ដំណើរការជំហានទី២។

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

ការចូលរួមរបស់ដៃគូរួមមាន ធនាគារពិភពលោក ដែលមានទឹកប្រាក់ចំនួន២៥.០៥លានដុល្លារ

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2020 | | 2021 | 2022 | 2023 | 2024 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2022-2024 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |
| **ចំណាយមូលធន** | 3,707.0 | 0.0 | 393.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 3,707.0 | 0.0 | 393.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 3,707.0 | 0.0 | 393.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2020 | | 2021 | 2022 | 2023 | 2024 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2022-2024 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 235.0 | 0.0 | 235.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 235.0 | 0.0 | 235.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | 3,472.0 | 0.0 | 158.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| World Bank | 3,472.0 | 0.0 | 158.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 3,707.0 | 0.0 | 393.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: